**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៥១ សណ.ឆក.ថក

# ប្រកាស

## ស្តីពី

## ការតព្វកិច្ចពាក់ម៉ាស និងការតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ក្នុងអំឡុងពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ



ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**ប្រការ១ ..**

ប្រកាសនេះ កំណត់អំពីបុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងរក្សាគម្លាតសុវត្ថិភាព និងទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាសនិងការអនុវត្តវិធានការរក្សាគម្លាតសុវត្ថិភាព ស្របតាមអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

**ប្រការ២ ..**

ប្រកាសនេះអនុវត្តសម្រាប់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ និងការឆ្លងរាលរាលនៃជំងឺនេះក្នុងកម្រិតសហគមន៍ផ្សេងទៀត។

## ជំពូកទី២
## បុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងរក្សាគម្លាតសុវត្ថិភាពបុគ្គល

**ប្រការ៣ ..**

បុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស រួមមាន៖

- បុគ្គលដែលមានវិជ្ជមានកូវីដ-១៩ ក្នុងពេលជួបផ្ទាល់ជាមួយមន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត
- បុគ្គលដែលមានកាតព្វកិច្ចធ្វើចត្តាឡីស័ក លើកលែងតែបុគ្គលនោះធ្វើចត្តាឡីស័កនៅក្នុងបន្ទប់ដាច់ដោយឡែកតែឯង និងមិនជួបផ្ទាល់ជាមួយអ្នកដទៃ
- អ្នកបើកបរយានគ្រប់ប្រភេទដែលជាមធ្យោបាយធ្វើដំណើររួម ឬមធ្យោបាយដឹកជញ្ជូនសម្រាប់បម្រើឱ្យសាធារណជន
- អ្នកដំណើរតាមមធ្យោបាយធ្វើដំណើររួម ឬមធ្យោបាយដឹកជញ្ជូនសម្រាប់បម្រើឱ្យសាធារណជន
- អ្នកផ្តល់សេវាផ្ទាល់ដល់អតិថិជន រួមមាន បុគ្គលិកជួរមុខនៅតាមសហគ្រាស ឬគ្រឹះស្ថាន ឬទីតាំងអាជីវកម្មនានា, មន្ត្រីនិងបុគ្គលិកសុខាភិបាល, អ្នកផ្តល់សេវាព្យាបាលដោយចលនា, បុគ្គលដែលបម្រើការនៅក្នុងភោជនីយដ្ឋានឬអាហារដ្ឋាន, បុគ្គលិកផ្ទះសំណាក់ឬសណ្ឋាគារ, បុគ្គលិកដែលផ្តល់សេវាម៉ាស្សា-កោសជប់ និងបុគ្គលផ្សេងទៀតដែលផ្តល់សេវាផ្ទាល់ជាមួយអតិថិជន និង
- បុគ្គលផ្សេងទៀតដែលកំពុងស្ថិតនៅតាមទីសាធារណៈដែលមានមនុស្សច្រើន ឬទីកន្លែងដែលមានការជួបជុំមនុស្សចាប់ពី ២ (ពីរ) នាក់ឡើងទៅ។

ប្រភេទនៃម៉ាស និងរបៀបនៃការពាក់ម៉ាស ត្រូវកំណត់តាមការណែនាំរបស់ក្រសួងសុខាភិបាល។
កាតព្វកិច្ចនៃការពាក់ម៉ាសដូចបានកំណត់ខាងលើ ត្រូវបានលើកលែងចំពោះករណី ដូចខាងក្រោម៖

- កុមារអាយុក្រោម ៦ (ប្រាំមួយ) ឆ្នាំ ដែលមិនមែនជាបុគ្គលដែលមានវិជ្ជមានកូវីដ-១៩ ឬជាបុគ្គលដែលមានកាតព្វកិច្ចធ្វើចត្តាឡីស័ក

- បុគ្គលដែលមិនអាចពាក់ម៉ាសបានដោយមូលហេតុកាយសម្បទា ឬមូលហេតុសុខភាពដោយមានការបញ្ជាក់ពីគ្រូពេទ្យ
- បុគ្គលដែលរស់នៅក្នុងលំនៅឋានឯកជនជាមួយគ្នា ក្នុងអំឡុងពេលនៃការជួបជុំគ្នានៅក្នុងលំនៅឋាននោះ
- ក្នុងអំឡុងពេលធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរឯកជនបិទជិតតែម្នាក់ឯង ឬជាមួយបុគ្គលដែលរស់នៅក្នុងលំនៅឋានជាមួយគ្នា
- សម្រាប់កីឡាករ-កីឡាការិនីក្នុងអំឡុងពេលកំពុងហាត់សម ឬពេលកំពុងប្រកួតកីឡា ក្នុងព្រឹត្តិការណ៍កីឡាផ្លូវការ ដែលការពាក់ម៉ាសមិនអាចធ្វើទៅបាន
- ក្នុងកាលៈទេសៈដែលមានការតម្រូវឱ្យដោះម៉ាសជាចាំបាច់ ដើម្បីបង្ហាញអត្តសញ្ញាណបុគ្គល ឬដើម្បីទទួលសេវាសុខាភិបាល ឬសេវាចាំបាច់ផ្សេងទៀត
- ក្នុងកាលៈទេសៈនៃសកម្មភាពដែលចាំបាច់ត្រូវដោះម៉ាស ជាអាទិ៍ នៅពេលបរិភោគអាហារ និងភេសជ្ជៈ ឬនៅពេលថតរូបសម្រាប់ប្រើប្រាស់ដើម្បីសម្គាល់អត្តសញ្ញាណក្នុងឯកសារផ្លូវការ ។

កាតព្វកិច្ចនៃការពាក់ម៉ាសនេះ ក៏អាចត្រូវបានលើកលែងផងដែរ ចំពោះសិល្បករ-សិល្បការិនីដែលត្រូវសម្តែងក្នុងកម្មវិធីសិល្បៈដែលត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ឬបុគ្គលដែលត្រូវបញ្ចេញមតិក្នុងកម្មវិធីឬកិច្ចប្រជុំផ្លូវការនានា ហើយដែលការពាក់ម៉ាសជាឧបសគ្គសម្រាប់ការនិយាយបញ្ចេញសម្លេងក្នុងលក្ខខណ្ឌដែលវិធានសុវត្ថិភាពសុខាភិបាលផ្សេងទៀត ជាអាទិ៍ ការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កំដៅ ការរក្សាគម្លាតសុវត្ថិភាព និងវិធានសុវត្ថិភាពដទៃទៀត ត្រូវបានធានាច្បាស់លាស់តាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីធានាការពារការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។

**ប្រការ៤** ..

បុគ្គលគ្រប់រូបដែលកំពុងស្ថិតនៅទីកន្លែងធ្វើការនៃសហគ្រាសឬគ្រឹះស្ថានឯកជន ទីតាំងអាជីវកម្ម ឬទីកន្លែងសាធារណៈនានា ដែលមានមនុស្សច្រើន ត្រូវមានកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល។ ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ត្រូវមានយ៉ាងតិច ១,៥០ម៉ែត្រ (មួយម៉ែត្រហាសិបសង់ទីម៉ែត្រ) ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់។

កាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល ត្រូវបានលើកលែងចំពោះករណី ដូចខាងក្រោម៖

- ក្នុងចំណោមបុគ្គលនានាដែលរស់នៅជាប្រចាំក្នុងលំនៅឋានជាមួយគ្នា
- ក្នុងអំឡុងពេលធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរឯកជន ក្នុងកាលៈទេសៈដែលការរក្សាគម្លាតសុវត្ថិភាពបុគ្គលមិនអាចធ្វើទៅបាន
- រវាងជនពិការ ចាស់ជរា ឬកុមារ ជាមួយនឹងអ្នកមើលថែទាំជនទាំងនេះ
- រវាងមន្ត្រីនិងបុគ្គលិកសុខាភិបាលដែលកំពុងផ្តល់សេវានៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈនិងឯកជន ជាមួយនឹងអ្នកជំងឺ ឬជាមួយអ្នកដែលមកទទួលសេវាសុខាភិបាល
- រវាងកូនកំលោះ និងកូនក្រមុំក្នុងពេលអំឡុងពេលធ្វើកិច្ចសាសនា និងប្រពៃណីនៃពិធីអាពាហ៍-ពិពាហ៍ ឬពិធីកំដាប់ពាក្យ ដែលត្រូវបានអនុញ្ញាតស្របតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច

- សម្រាប់កីឡាករ-កីឡាការិនីក្នុងអំឡុងពេលកំពុងហាត់សម ឬពេលកំពុងប្រកួតកីឡា ក្នុងព្រឹត្តិការណ៍កីឡាផ្លូវការនានា ដែលការរក្សាគម្លាតសុវត្ថិភាពមិនអាចធ្វើទៅបាន
- រវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវា ក្នុងអំឡុងពេលបំពេញសកម្មភាពការងារ ឬមុខរបរផ្សេងទៀតដែលការរក្សាគម្លាតសុវត្ថិភាពបុគ្គលមិនអាចធ្វើទៅបាន ជាអាទិ៍ សេវាព្យាបាលដោយចលនា ឬសេវាកម្មថែរក្សាសម្ផស្ស ឬកាត់សក់ ជាដើម។

**ប្រការ៥** ..

ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ក៏ត្រូវអនុវត្តផងដែរនៅពេលធ្វើដំណើរក្នុងមធ្យោបាយដឹកជញ្ជូនរួម ឬមធ្យោបាយដឹកជញ្ជូនសម្រាប់បម្រើឱ្យសាធារណជន។ ក្នុងកាលៈទេសៈដែលការរក្សាគម្លាតសុវត្ថិភាពមិនអាចធ្វើទៅបានចំពោះការធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនរួម ឬមធ្យោបាយដឹកជញ្ជូនសម្រាប់បម្រើឱ្យសាធារណជន បុគ្គលដែលធ្វើដំណើរត្រូវមានកាតព្វកិច្ចពាក់ម៉ាស និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កំដៅ ដើម្បីជាវិធានការក្នុងការបង្ការការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។

**ប្រការ៦** ..

ក្នុងករណីដែលស្ថានភាពរបស់បុគ្គលតម្រូវថាបុគ្គលនោះមិនអាចពាក់ម៉ាសបាន ដោយមូលហេតុដូចបានកំណត់ក្នុងកថាខណ្ឌទី៣ និងកថាខណ្ឌទី៤ នៃប្រការ៣ នៃប្រកាសនេះ បុគ្គលនោះត្រូវមានកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ដើម្បីជាវិធានការក្នុងការបង្ការការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។

ក្នុងករណីដែលការរក្សាគម្លាតសុវត្ថិភាពបុគ្គលមិនអាចធ្វើទៅបាន ដោយមូលហេតុដូចបានកំណត់ក្នុងកថាខណ្ឌទី២ នៃប្រការ៤ នៃប្រកាសនេះ បុគ្គលនោះត្រូវមានកាតព្វកិច្ចពាក់ម៉ាស និងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ដើម្បីជាវិធានការក្នុងការបង្ការការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។

ចំពោះបុគ្គលដែលត្រូវបានលើកលែងឱ្យរួចផុតពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ដូចមានកំណត់ក្នុងកថាខណ្ឌទី៣ និងកថាខណ្ឌទី៤ នៃប្រការ៣ និងកថាខណ្ឌទី២ នៃប្រការ៤ នៃប្រកាសនេះ ត្រូវបានប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត ដើម្បីបង្ការការចម្លងឬការឆ្លងមេរោគកូវីដ-១៩។

## ជំពូកទី៣
## ទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាស និង
## ទីកន្លែងដែលតម្រូវឱ្យមានការរក្សាគម្លាតសុវត្ថិភាព

**ប្រការ៧** ..

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម រួមមានជាអាទិ៍ ភោជនីយដ្ឋាន-អាហារដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ គ្លីនិក ឬមន្ទីរសម្រាកព្យាបាលជំងឺ ឱសថស្ថាន ផ្សារទំនើប ហាងលក់ទំនិញ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រោងចក្រ សិប្បកម្ម ឬទីកន្លែងធ្វើការ ឬទីកន្លែងអាជីវកម្មដទៃទៀត ត្រូវត្រួតពិនិត្យ និងណែនាំបុគ្គលិក និងបុគ្គលគ្រប់រូប ដែលចូលទៅទីកន្លែងរបស់ខ្លួន ឱ្យធ្វើការពាក់ម៉ាស ហើយមិនត្រូវ

អនុញ្ញាតឱ្យបុគ្គលដែលមិនពាក់ម៉ាសចូលក្នុងទីកន្លែងរបស់ខ្លួនឡើយ លើកលែងតែចំពោះបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចពាក់ម៉ាស ដូចមានចែងកថាខណ្ឌទី៣ និងទី៤ នៃប្រកា៣ នៃប្រកាសនេះ។

**ប្រការ៨ ..**

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវរៀបចំនៅក្នុងទីតាំងរបស់ខ្លួន ដើម្បីធានាថាបុគ្គលិក និងអតិថិជន អាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល នៅពេលរង់ចាំចូល និងពេលកំពុងស្ថិតក្នុងទីកន្លែងរបស់ខ្លួន លើកលែងតែចំពោះបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គលដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការ ៤ នៃប្រកាសនេះ។ រាល់សហគ្រាស ឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម មិនត្រូវទទួលអតិថិជនលើសពីចំនួន ដែលអាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គលនៅក្នុងទីកន្លែងរបស់ខ្លួនឡើយ។

**ប្រការ៩ ..**

ក្នុងករណីដែលកម្មវិធីសាសនា កម្មវិធីប្រពៃណី កម្មវិធីកីឡា ឬកម្មវិធីកំសាន្ត មិនត្រូវបានហាមឃាត់ឱ្យមានការរៀបចំ អ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ត្រូវសហការ និងអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តវិធានសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេស ការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្ដៅ ការពាក់ម៉ាស ការរក្សាគម្លាតសុវត្ថិភាព និងការកាត់បន្ថយចំនួនមនុស្សចូលរួមឱ្យនៅកម្រិតអប្បបរមា និងចៀសវៀងការជួបជុំដែលមានលក្ខណៈកុះករកកកុញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ជំពូកទី៤
## ទីតាំងភូមិសាស្ត្រដែលត្រូវអនុវត្តកាតព្វកិច្ចពាក់ម៉ាស
## និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព

**ប្រការ១០ ..**

កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពដូចមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃប្រកាសនេះ ត្រូវអនុវត្តក្នុងភូមិសាស្ត្រដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ដែលត្រូវកំណត់តាមការជូនដំណឹងរបស់ក្រសួងសុខាភិបាល។

**ប្រការ១១ ..**

ចំពោះភូមិសាស្ត្រដែលមិនមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ បុគ្គលគ្រប់រូបត្រូវបានលើកទឹកចិត្តឱ្យប្រកាន់ខ្ជាប់នូវ វិធានការ "៣ការពារ និង៣កុំ" ដើម្បីបង្ការការចម្លងឬការឆ្លងមេរោគកូវីដ-១៩។

វិធានការ "៣ ការពារ" រួមមាន៖

១. ត្រូវលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬទឹកអាកុល ឬអាកុលដែលឱ្យបានលើសពី ៧០ដឺក្រេ ក្នុងមួយថ្ងៃ

២. ត្រូវពាក់ម៉ាស ត្រូវខ្ទប់មាត់ និងច្រមុះនៅពេលក្អក កណ្ដាស់ ដោយប្រើម៉ាស ប្រើកែងដៃ ឬប្រើក្រដាសជូតមាត់ ហើយត្រូវបោះចោលក្នុងធុងសំរាមបិទជិតត្រឹមត្រូវ



H

៣. ត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គលឲ្យបានយ៉ាងតិច ១.៥ ម៉ែត្រឡើង ទៅពីម្នាក់ទៅម្នាក់។

វិធានការ "៣ កុំ" រួមមាន៖

១. កុំទៅកន្លែងដែលបិទជិត គ្មានខ្យល់ចេញចូល ហើយប្រើម៉ាស៊ីនត្រជាក់ច្រើន

២. កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ ឬការជួបប្រជុំគ្នាច្រើន ឬពិធីដែលមានគ្នាច្រើន

៣. កុំនៅជិត ឬក្បែរគ្នា ឬប៉ះពាល់គ្នា ឬកុំឱបគ្នា ឬកុំចាប់ដៃគ្នា ដោយត្រូវប្រើវិធីសំពះគ្នា លើកដៃជាសញ្ញា ឬងក់ក្បាល ជាដើម។

## ជំពូកទី៥
## ការអនុវត្តទោសប្បញ្ញត្តិ

**ប្រការ១២ ..**

បុគ្គលដែលមិនអនុវត្តកាតព្វកិច្ចនៃការពាក់ម៉ាស ឬកាតព្វកិច្ចនៃការរក្សាគម្លាតសុវត្ថិភាព ដូចមានចែងក្នុងពីប្រការ៣ ដល់ប្រការ៩ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

**ប្រការ១៣ ..**

ការព្រមាន និងការណែនាំដល់បុគ្គលដែលមិនអនុវត្តកាតព្វកិច្ចនៃការពាក់ម៉ាស ឬកាតព្វកិច្ចនៃការរក្សាគម្លាតសុវត្ថិភាព ត្រូវធ្វើឡើងដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានកាតព្វកិច្ចនៃការពាក់ម៉ាស ឬកាតព្វកិច្ចនៃការរក្សាគម្លាតសុវត្ថិភាព ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

## ជំពូកទី៦
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**ប្រការ១៤ ..**

កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ដូចមានចែងក្នុងប្រកាសនេះ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ១៥ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦** ..

ខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល គ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៥កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០២១

ម៉ម ប៊ុនហេង

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ដូចប្រការ១៦
- ឯកសារ កាលប្បវត្តិ